ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៦១.០១៩.៤២៧.ស.ជ.ណ

ថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែតុលា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង ស្តីពី

## ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ

## "១០ តុលា ១៩៧៩ - ១០ តុលា ២០១៩"

ធនាគារជាតិនៃកម្ពុជា មានកិត្តិយស សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នៅថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ខាងមុខនេះ ធនាគារជាតិនៃកម្ពុជានឹងប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ "១០ តុលា ១៩៧៩ - ១០ តុលា ២០១៩" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅសាលសន្និសីទចតុមុខ។

ពិធីនេះមានការអញ្ជើញចូលរួមពីសំណាក់សមាជិក សមាជិកា រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល អង្គទូត តំណាងអង្គការជាតិនិងអន្តរជាតិ ថ្នាក់ដឹកនាំនិងមន្ត្រីធនាគារជាតិនៃកម្ពុជា សរុបប្រមាណ ៦០០នាក់។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកការិយាល័យទំនាក់ទំនង នៃនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈអ៊ីម៉ែល៖ nbccommunication@nbc.org.kh ឬ លេខទូរស័ព្ទ៖ ០២៣ ៩៨០ ១៩៦។